N° 12
– Kambujasuriya –
R. le 12-2-54-
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

INSTITUT BOUDDHIQUE

Décembre

ឆ្នាំទី ២៥ ខែធ្នូ លេខ ១២

ព.ស. ២៤៩៦ – គ.ស. ១៩៥៣

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K.1
1953_12

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — សាធុរក្ខណកថា .................. | ព្រះគ្រូសិរីសោភ័ណ កិម – តូរ .. | ៨៨៦ |
| — នានាសារធម៌ ................ | លោក ស៊ុន - ហ៊ីន ........ | ៨៩៥ |
| — ទេវតា ... មានមែនឬទេ ....... | លោក ប៊ូ - ប៊ូ ........... | ៩០០ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — ដំបូន្មានរំលឹកជនរួមជាតិ .......... | លោក អ៊ុង - ស៊ុមន៍ ........ | ៩១០ |
| — ការបណ្ដុះនិស្ស័យ (តមក) ........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង – ប៉ម ... | ៩២៣ |
| — រឿងសាមកុក (តមក) .......... | ឧកញ៉ា នូ – កន .......... | ៩២៧ |
| — រឿងអារក្សថ្លែងរឿងខ្លែប្រាំ (តចប់) .... | លោក ភ៉យ – ប៊ុក ......... | ៩៣១ |
| — រឿងចិញ្ចៀនទិព្យ (តមក) .......... | អ្នកស្រីសាវីយ៉ាន់ ......... | ៩៣៩ |
| — រឿងប៉ូលនឹងវីរ៍ស៊ីនី (តមក) ....... | លោក ផេង - ជ្រីវ ......... | ៩៤៤ |
| — សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីពាក្យ វ៉ូន ......... | លោកតាប - ពិន .......... | ៩៤៨ |
| **កំណត់ទិនប្រវត្តិការណ៍** | | |
| — ព្រះរាជប្រវត្តិនិងសេចក្ដីអស្ចារ្យ នៃព្រះ ប្រិយមហាក្សត្រ ............... | ព្រះគ្រូអនុគណ កែ - អ៊ឿន ... | ៩៥៧ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

សាធុរក្ខណគាថា

# ព្រះគ្រូសិរីសោភ័ណ កិម-តូរ ក្រុមជំនុំព្រះត្រៃបិដក

ទេសនាផ្សាយវិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ ៨ រោច ខែជេស្ឋ ឆ្នាំឆ្លូវឯកស័ក

ព.ស. ២៤៩២ (១៩-៦-៤៩)

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌នឹងព្រះអរិយសង្ឃ ដោយគោរព) ។

វេលានេះ អាត្មាភាពសូមសំដែងពុទ្ធភាសិតមួយបទ ត្រង់បាលីថា

រក្ខេយ្យ អត្តនោ សាធុំ លវនំ លោណតំ យថា ប្រែថា "បុគ្គលគប្បីរក្សាសេចក្តីល្អរបស់ខ្លួនទុក ដូចជាអំបិលរក្សារសប្រៃរបស់-ខ្លួន" ។

អាត្មាភាពសូមអធិប្បាយពង្រីកសេចក្តីនៃពុទ្ធភាសិតនេះ ឲ្យពិស្តារ ល្មមជាទីសវនាការនៃអស់លោក-អ្នកជាពុទ្ធសាសនិកជន ដូចតទៅនេះ:

ពាក្យថា "រក្សាសេចក្តីល្អរបស់ខ្លួនទុក" នោះ បានដល់ការរក្សាសេចក្តីល្អដោយមិនធ្វើសេចក្តីអាក្រក់ គឺធ្វើតែសេចក្តីល្អម្យ៉ាងឲ្យកើតចំរើនឡើង យ៉ាងនេះហៅថារក្សាសេចក្តីល្អរបស់ខ្លួនទុក ។ ពាក្យថា "ដូចជាអំបិលរក្សារសប្រៃរបស់ខ្លួន" នោះ ធម្មតាអំបិលជាធម្មជាតិមានរសប្រៃ បើទុកជាគេយកទៅទុកដាក់លាយឡំ ច្របូកច្របល់ជាមួយនឹង

វត្ថុផ្សេងៗ មានរសផ្អែមល្វីងជូរចត់ជាដើម អំបិលក៏មិនប្រែក្លាយទៅតាម វត្ថុទាំងនោះឡើយ នៅតែរក្សារសប្រៃរបស់ខ្លួនដដែល ៗ រួមសេចក្ដីថា បុគ្គលត្រូវតែរក្សាសេចក្ដីល្អរបស់ខ្លួនទុក ឲ្យដូចជាអំបិលដែលរក្សារសប្រៃរបស់ខ្លួនទុក ដូច្នោះឯង ។

ធម្មតាមនុស្សក្នុងលោកសន្និវាសនេះ មិនថាជាន់ខ្ពស់ជាន់កណ្ដាលជាន់ទាបទេ ទោះមនុស្សប្រភេទណាក៏ដោយ សុទ្ធសឹងតែជាអ្នកត្រូវការចង់បានសុខភាពនឹងវឌ្ឍនភាពដូចៗគ្នាទាំងអស់ ប៉ុន្តែការស្វែងរកសេចក្ដីល្អនោះគេមិនងឹងជួបប្រទះបានដោយងាយ ច្រើនតែបះពារទៅលើឧបសគ្គផ្សេងៗពីគ្នា ។ ការស្វែងរកសេចក្ដីល្អនោះ ខំធ្វើដោយប្រារព្ធយកខ្លួនជាធំ ហៅថា អត្តាធិបតេយ្យក៏មាន, ខំធ្វើដោយប្រារព្ធយកលោកជាធំ ហៅថា លោកាធិបតេយ្យក៏មាន, ខំធ្វើដោយប្រារព្ធយកធម៌គឺច្បាប់ជាធំ ហៅថា ធម្មាធិបតេយ្យក៏មាន ។

ដូចម្ដេចដែលហៅថា ធ្វើសេចក្ដីល្អដោយប្រារព្ធយកខ្លួនជាធំ?

បុគ្គលពួកខ្លះក្នុងលោកនេះ បើនឹងផ្ដើមធ្វើកិច្ចការអ្វីទោះជាផ្លូវលោកក្ដីផ្លូវធម៌ក្ដី ដែលខ្លួនសំគាល់យល់ថាជាអំពើល្អហើយក៏ធ្វើទៅ តែការសំគាល់នោះជួនកាលក៏ត្រូវ ជួនកាលក៏ខុស; ព្រោះហេតុអ្វី? ព្រោះធម្មតាគំនិតរបស់មនុស្សម្នាក់ៗ ដែលផ្ដើមគិតការអ្វីមួយៗ មិនមែនសុទ្ធតែត្រូវគ្រប់យ៉ាងទាំងអស់ទេ គង់មានភ្លាំងភ្លាត់ខ្លះមិនខាន ហេតុនោះ

ការតាំងមានះប្រកាន់យកខ្លួន ឬលើកខ្លួនជាធំសម្រេចកិច្ចការគ្រប់ជំពូក មិនរវល់អើពើពាក្យទូន្មានអ្នកដទៃ មិនអើពើច្បាប់ប្រាប់ខុសត្រូវ យកជំនះតែខ្លួនឯង ឯកិច្ចការនោះ ៗ រមែងសម្រេចប្រយោជន៍បានល្អខ្លះ មិនល្អខ្លះ ដូច្នេះទើបហៅថាជាអ្នករក្សាសេចក្ដីល្អរបស់ខ្លួនទុកដោយបរិបូណ៌ពុំបានឡើយ ។

ត្រង់ពាក្យថា "ខ្វះធ្វើការដោយប្រាជ្ញាយកលោកជាធំ" ៗ លោក ក្នុងនេះ បានដល់មនុស្សប្រុសស្រីទាំងគ្រហស្ថទាំងបព្វជិត ; បុគ្គលណាធ្វើកិច្ចការអ្វីមួយ ធ្វើដោយតម្រូវចិត្តរបស់មនុស្ស មិនតម្រូវតាមច្បាប់ បុគ្គលនោះទើបហៅថាជាអ្នករក្សាសេចក្ដីល្អរបស់ខ្លួនទុកដោយគ្រប់គ្រាន់ពុំបានឡើយ ។

បុគ្គលអ្នកធ្វើសេចក្ដីល្អ ត្រូវកុំធ្វើដោយប្រាជ្ញាយកខ្លួនជាធំ គឺកុំមានះធ្វើតាមតែគំនិតខ្លួនម្នាក់ឯង ត្រូវកុំធ្វើដោយប្រាជ្ញាយកលោកជាធំ គឺកុំធ្វើដោយខ្លាចគេនិន្ទា ត្រូវធ្វើដោយប្រាជ្ញាយកច្បាប់ជាធំ យកច្បាប់ជាគោលពិតៗ ទើបសេចក្ដីល្អនោះនឹងអាចតាំងនៅខ្ជាប់ខ្ជួនអស់កាលដ៏យូរទៅបាន ; ព្រោះបុគ្គលអ្នកធ្វើសេចក្ដីល្អដោយប្រាជ្ញាយកខ្លួនជាធំនឹងប្រាជ្ញាយកលោកជាធំ រមែងមិនបានតាំងនៅមាំក្នុងសេចក្ដីល្អនោះឡើយ កាលបើមានអារម្មណ៍គួរប្រាថ្នាចូលមកដល់ខ្លួនហុចឲ្យ ឬមានភ័យគួរខ្លាចចូលមកតម្រាមហើយរមែងលះសេចក្ដីល្អនោះចោល ; ព្រោះហេតុនោះ បុគ្គល

អ្នកប្រាថ្នាសេចក្ដីល្អគឺសេចក្ដីសុខនិងសេចក្ដីចំរើនឲ្យកើតឡើងដល់ខ្លួននិងអ្នកដទៃ ត្រូវតែតស៊ូកុំញញើតកុំតក់ស្លុតនឹងឧបសគ្គផ្សេងៗ ។ ក្នុងពេលដែលកំពុងប្រព្រឹត្តធម៌នោះត្រូវដឹងខ្លួនថា បើទុកជាគេយកទ្រព្យនឹងយកស័ក្ដិជាដើមមកល្បួងលួងលោមប្រគល់ឲ្យក្ដី ឬគេយកអំណាចមកផ្ដួញ-ផ្ដាល់គម្រាមផាកក្ដី បុគ្គលអ្នកប្រាថ្នាសេចក្ដីល្អ កុំគប្បីកន្ត្រាក់គំនិតទៅត្រេកអរនឹងវត្ថុទាំងនោះ ឬតក់ស្លុតខ្លាចអំណាចនោះឡើយ ត្រូវតែជំនះឈានកន្លងឧបសគ្គផ្សេងៗ នោះឲ្យបាន ទើបឈ្មោះថាជាអ្នករក្សាសេចក្ដីល្អរបស់ខ្លួន បើមិនដូច្នោះទេ នឹងរក្សាសេចក្ដីល្អរបស់ខ្លួនទុកឲ្យគង់គ្រាន់ពុំបានឡើយ ។

អស់លោកសប្បុរសអ្នកស្តាប់គួរជ្រាបថា ធម្មតាមនុស្សក្នុងសកល-លោកដែលផ្ដើមធ្វើការអ្វីមួយ ទោះខាងផ្លូវលោកក្ដី ខាងផ្លូវធម៌ក្ដី រមែងតែមានគំនិតគោលដៅមុខដើម្បីរកសេចក្ដីចំរើនរៀងៗខ្លួន តែគំនិតរបស់បុគ្គលពួកខ្លះដើរត្រង់ផ្លូវស្អាតល្អ បើនឹងធ្វើអ្វីគឺមានបំណងចង់ឲ្យបានប្រយោជន៍គឺសេចក្ដីសុខ និងសេចក្ដីចំរើនកើតឡើងដល់ខ្លួននិងអ្នកដទៃផង យកច្បាប់ជាធំជាប្រមាណផង យ៉ាងនេះក៏មាន គំនិតរបស់បុគ្គលពួកខ្លះជាគំនិតវៀចវេរកុងកាច់កោងដូចដងអន្ទាក់ ឬវៀចក្ងិចក្ងក់ដូចអន្លង់កាំង រមែងប្រចាំងគ្នារកមកក្នុងលោក បើនឹងធ្វើអ្វីប្រឹងតែបៀតបៀនគេឲ្យវិនាស ឬស្វែងរកទោសសង្កត់សង្កិនគេឲ្យរួញរាថយកម្លាំង ដើម្បីឲ្យកើត

ប្រយោជន៍ដល់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ដោយកាន់ទ្រព្យសម្បត្តិ ឬកាន់យសស័ក្តិ ឬកំឡាំងបគេនិទ្ធា ពុំនោះចង់ឲ្យគេសរសើរជាដើម យ៉ាងនេះក៏មាន ៗ

បពិត្រអស់លោកសប្បុរសទាំងឡាយ ! បើលោកអ្នកត្រូវការរក្សាសេចក្តីល្អ សូមជំរះកាយវាចាចិត្តឲ្យបរិសុទ្ធស្អាតតាមកុសលកម្មបថ ១០ ហើយដើរតាមផ្លូវត្រង់ បើទុកជាដល់ទង្គិចប៉ះពារទៅលើគំនិតទុច្ចរិតរបស់អ្នកដទៃ បណ្តាលឲ្យកើតទៅជាទោសក្តី ដូចប្រទះនឹងលាភៈសក្ការៈជារបស់គួរប្រាថ្នាក្តី ត្រូវញាំងចិត្តកុំឲ្យរំភើបរញ្ជួយ ឬត្រេកអរនឹងរបស់ទាំងនោះឡើយ បើមិនដូច្នោះទេ នឹងតាំងខ្លួនជាអ្នករក្សាសេចក្តីល្អ ឬស្វែងរកសេចក្តីល្អដូចម្តេចបាន ប្រៀបដូចអ្នកធ្វើផ្លូវថ្នល់ពីភូមិមួយទៅកាន់ភូមិមួយ ពីស្រុកមួយទៅកាន់ស្រុកមួយ បើចង់ឲ្យថ្នល់មានសណ្ឋានត្រង់ស្រួល ថ្នល់នោះឯងកាលបើចាប់ធ្វើទៅហើយ រមែងតែប៉ះពារទៅលើដីទាបនឹងដីខ្ពស់ខ្លះ ប៉ះពារទៅលើដើមឈើតូចធំនឹងព្រៃញាតស្បាតខ្លះ ប៉ះពារទៅលើដំណាំដាំដុះនឹងដីភូមិផ្ទះសម្បែងរបស់អ្នកស្រុកជាដើមខ្លះ, ការប៉ះពារទៅលើវត្ថុផ្សេង ៗ ដូច្នេះជាធម្មតានៃការធ្វើថ្នល់; អ្នកធ្វើថ្នល់បើមានសេចក្តីខ្លាចរញ្ជួយ ប្រទះដីទាបមិនលើកបំពេញ ប្រទះដើមឈើតូចធំនឹងព្រៃញាតស្បាតមិនកាប់ឆ្ការរំលាយចេញ ប្រទះដីភូមិផ្ទះសម្បែងរបស់អ្នកស្រុកមិនឲ្យគេរុះរើចេញទេ ហើយធ្វើ

ដោយការបៀសកង់ដូច្នេះ ចិត្តនោះឯងមុខតែវៀចកោងក្ងិចក្ងក់មិនត្រង់ស្មើឡើយ, បើចង់ឲ្យចិត្តនោះមានសណ្ឋានត្រង់ស្មើលុះតែកុំធុញទ្រាន់កុំរួញកនឹងវត្ថុដែលជាគ្រឿងទើសទាស់ផ្សេងៗ ពីខាងមុខ បើទើសទាស់នឹងអ្វីត្រូវតែកំចាត់បង់របស់នោះចេញ ទើបចិត្តនោះឯងមានសណ្ឋានត្រង់ស្មើទៅបាន: សេចក្ដីប្រៀបនេះយ៉ាងណា, បុគ្គលអ្នកស្វែងរកសេចក្ដីល្អ គឺប្រយោជន៍ខាងផ្លូវលោកដូចធ្វើស្រែធ្វើចំការប្បារដំណាំផ្សេងៗក្ដី ធ្វើជំនួញជួញតាមជើងទឹកនឹងជើងគោកក្ដី ឬស្វែងរករៀនចំណេះអ្វីផ្សេងៗក្ដី ការស្វែងរកនោះៗ រមែងមានសេចក្ដីព្រួយនឿយហត់លំបាកជាធម្មតា ប៉ុន្តែនឹងគេចបៀសកង់ពុំបាន ក្នុងវេលាកំពុងស្វែងរកនោះ ជួនកាលក៏បានសម្រេចប្រយោជន៍សមតាមប្រាថ្នាក៏មាន ជួនកាលជួបប្រទះទៅលើឧបសគ្គគឺអន្តរាយផ្សេងៗ ចូលមកបៀតបៀនធ្វើឲ្យអាក់ខានឃ្លាងបាត់ប្រយោជន៍ក៏មាន តែបើយើងខ្លាចតក់ស្លុតញញើតរួញកនឹងឧបសគ្គនោះៗ ហើយ ប្រយោជន៍ដែលត្រូវបានក៏បែរទៅជាឃ្លាងឃ្លាតសូន្យទទេទៅវិញ ; ហេតុនោះបុគ្គលអ្នកស្វែងរកប្រយោជន៍គឺសេចក្ដីល្អនឹងសេចក្ដីចំរើន ត្រូវតែអធិដ្ឋានតាំងទុកក្នុងចិត្តថា សេចក្ដីល្អដែលអាត្មាអញប្រព្រឹត្តធ្វើនេះ បើទុកជាគេយកទ្រព្យឬយសសក្ដិមកល្បួងលួងលោមក្ដី ឬមានឧបសគ្គណាមួយចូលមកបៀតបៀនក្ដី អាត្មាអញមិនត្រូវក័ន្តគំនិតទៅត្រេកអរនឹងវត្ថុទាំងនោះ តាំង

មិនត្រូវរញ្ញាកឲ្យខូចសេចក្តីល្អរបស់អាត្មាអញឡើយ ត្រូវតែជំនះឈានកន្លងឧបសគ្គនោះៗ ដរាបទាល់តែបាន ទើបឈ្មោះថាជាអ្នករក្សាសេចក្តីល្អរបស់ខ្លួនឲ្យតាំងនៅខ្ជាប់ខ្ជួន អស់កាលជាអង្វែងទៅ ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត បុគ្គលអ្នករក្សាសេចក្តីល្អខាងផ្លូវធម៌ពិតសាសនា គួរប្រាប់ខ្លួនថា គុណធម៌ពិតសេចក្តីល្អណាមួយដែលខ្លួនបានប្រព្រឹត្តធ្វើមក អស់កាលដ៏យូរហើយក្តី កំពុងប្រព្រឹត្តធ្វើក្តី នឹងត្រូវប្រព្រឹត្តធ្វើតទៅខាងមុខទៀតក្តី តាំងចិត្តប្រព្រឹត្តធ្វើឲ្យខ្ជាប់ខ្ជួនឲ្យរឹងរឹតតែកើនចំរើនឡើង កុំបន្ថយបន្ធូរលះបង់ចោលដោយសារហេតុណាមួយ ចូលមកបៀតបៀននោះឡើយ ។ ពុំនោះសោតបើទុកជាខ្លួននៅក្នុងចំណោមមនុស្សអន្ធពាលល្ងង់ខ្លៅអាប់ឥតប្រាជ្ញា មានទិដ្ឋិលាមកអាក្រក់ប្រកាន់ខុសឃ្លៀងឃ្លាតចាកធម៌វិន័យយ៉ាងណា ក៏នៅតែតាំងចិត្តប្រព្រឹត្តសុចរិតល្អត្រឹមត្រូវ ដោយកាយ វាចា ចិត្ត ជាដរាប មិនអើពើលុះក្នុងអំណាចនៃមនុស្សអន្ធពាលនោះឡើយ ; សេចក្តីនេះ លោកប្រៀបដូចផ្កាឈូក ធម្មតាឈូកជាតិណាជាតិមានក្លិនក្រអូបល្អ បើទុកជាដុះកើតនៅត្រង់កន្លែងសំអុយដែលជាកន្លែងនឹមហាជនតែងយកសម្រាម ឬវត្ថុមានក្លិនស្អុយមិនស្អាតគួរខ្ពើមរអើមទៅចាក់ចោលក៏ដោយ ឈូកនោះឯងវេលាមានផ្កាឡើង ឥតចេះប្រែក្លាយទៅតាមគ្រឿងសំអុយទាំងនោះឡើយ នៅតែរក្សាជាតិរបស់ខ្លួនមាន

ក្លិនក្រអូបដែល រមែងជាទីរីករាយស្រឡាញ់ពេញចិត្តនៃជនទាំងឡាយ មានក្រស្រិយ៍និងមន្ទ្រីជាដើម ជាផ្កាមានលំអគួរគេលើកដំកល់លើក្បាល ដំណេកបាន មានឧបមាយ៉ាងណា, បុគ្គលអ្នកស្តាប់សិក្សារៀនសូត្រ តាមពុទ្ធវចនៈហើយប្រព្រឹត្តល្អស្អាតដោយកាយ វាចា ចិត្ត ហៅថាជា សាវ័ករបស់ព្រះសម្មាសម្ពុទ្ធ សាវ័កនោះឯង បើទុកជាកើតនៅក្នុង ចំណោមនៃមហាជនល្ងង់ខ្លៅងងឹតអាប់អួរប្រាជ្ញា ឬមនុស្សដែលមានគំនិត របិញរបុញប្រព្រឹត្តអាក្រក់គគ្រក់ដូចជាគំនរសម្រាមក៏ដោយ លោកក៏មិន មែនសម្ងំត្រានៅដោយសេចក្តីងងឹតល្ងង់ដូចជាមហាជនទាំងនោះឡើយ លោករមែងពិចារណាឃើញទោសក្នុងកាម និងអានិសង្សក្នុងការ ចេញចាកកាមហើយទៅបួស វេលាបួសហើយមិនព្រមត្រេកអរត្រឹម ផ្នួសដែលបានបួសប៉ុណ្ណោះ ទំប្រឹងព្យាយាមសំអិតសំអាតសីលឲ្យបាន បរិសុទ្ធហើយធ្វើសមាធិនិងបញ្ញា ដរាបដល់បាននិមុត្តិនិងវិមុត្តិញាណ ទស្សនៈ ហើយក៏ទំលាយគំនរអវិជ្ជា គឺសេចក្តីងងឹតល្ងង់ខ្លៅឲ្យឃ្លាតចាក សន្តាន ហើយបានធ្វើគុណវិសេសគឺលោកុត្តរធម៌ ឲ្យកើតនៅក្នុង កណ្តាប់ដៃរបស់ខ្លួនបាន ហើយក៏សម្រេចជាអគ្គទក្ខិណេយ្យបុគ្គល ដ៏ ប្រសើរក្នុងព្រះពុទ្ធសាសនា ជាអ្នកគួរទទួលនូវការគោរពបូជាអំពីទេវតា និងមនុស្សទាំងឡាយ យ៉ាងប្រពៃក៏មានឧបមេយ្យដូច្នោះឯង ។

ន័យមួយទៀត ការរក្សាសេចក្តីល្អនេះ បើនឹងអធិប្បាយឲ្យឆ្ងាយ ស្តាប់កន្លងធម៌ទេសនានេះ ដូចអស់លោកសប្បុរសជាពុទ្ធមាមកជន ធ្លាប់មានចរិយាការប្រព្រឹត្តសុចរិតដោយផ្លូវកាយ វាចា ចិត្ត ព្រមទាំងបុគ្គលិកលក្ខណៈ ពាសុភាពមានសណ្តាប់ធ្នាប់ រៀបរយល្អមកស្រាប់ហើយក្តី ធ្លាប់បានប្រព្រឹត្តធ្វើកុសលណាមួយ មានទាននឹងសីលជាដើមមកស្រាប់ហើយក្តី បើទុកជាខ្លួនមានគ្រោះថ្នាក់គឺសេចក្តីអន្តរាយផ្សេងៗ ចូលមកបៀតបៀនយ៉ាងណា ក៏នៅតែមិនព្រមលះចរិយានឹងកុសលនោះៗ ឲ្យសាបរលាបបាត់ទៅវិញឡើយ ប្រៀបដូចជាអំបិលដែលមិនលះបង់ជាតិប្រៃរបស់ខ្លួនដោយសារត្រូវដៃដូច្នោះឯង ។

ធម្មទេសនាដែលអាត្មាភាពសម្តែងមកហើយនេះ ល្មមសមគួរដល់វេលាហើយ, សូមបញ្ចប់ដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

តេ អត្ថលទ្ធា សុខិតា វិរុឡ្ហា ពុទ្ធសាសនេ
អរោគា សុខិតា ហោថ សហ សព្វេហិ ញាតិភិ ។

លោកអ្នកទាំងឡាយជាសប្បុរស សូមបាននូវប្រយោជន៍នឹងសេចក្តីសុខគ្រប់ប្រការ សូមចំរើនលូតលាស់ក្នុងព្រះពុទ្ធសាសនា សូមកុំឲ្យមានរោគ សូមឲ្យមានតែសេចក្តីសុខម្យ៉ាង ព្រមទាំងញាតិទាំងឡាយគ្រប់ៗគ្នា! ។

## នានាសារធម៌

(ស្រង់ចាកច្បាប់ផ្សេងៗ មានធម្មបទខុទ្ទកនិកាយជាដើម)

របស់

# លោក សុន-ហាន ចៅគ្រូសាសនបណ្ឌិត្យ

---

១ – មាតាបិតាជាអ្នកមានគុណដល់បុត្តធីតា ត្រូវដឹងថាគុណលោកនឹងតបមិនអស់, ដ្បិតលោកជាបុព្វការីជនជាព្រហ្មរបស់យើងជាបុត្តធីតា ព្រោះដូច្នោះ យើងជាបុត្តធីតាគួរតបសងធ្វើសក្ការបូជាលោក តាមឋានៈនោះៗ ទើបឈ្មោះថាកតញ្ញូ កតវេទិបុគ្គល ។

២ – មនុស្សកើតមកហើយ ត្រូវមានកិច្ចការ ធ្វើដូចគ្នាទាំងអស់ វៀរលែងតែច្រើនឬតិច សម្រេចឬមិនសម្រេចប៉ុណ្ណោះ ដូច្នោះគួរយើងជ្រើសរើសធ្វើកិច្ចការណាដែលជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ កុំធ្វើខ្លួនឲ្យជាមនុស្សបង្អៀតលោក គឺមនុស្សមិនបានការ ។

៣ – ការប្រដាប់តាក់តែងខាងក្រៅ មិនជារបស់សំខាន់ប៉ុន្មានទេ ព្រោះធ្វើមនុស្សដទៃឲ្យល្អតែមួយកាលប៉ុណ្ណោះ ស៊ូនឹងសេចក្តីចេះដឹងសេចក្តីប្រព្រឹត្តល្អមិនបានទេ ព្រោះសេចក្តីចេះដឹង-សេចក្តីប្រព្រឹត្តល្អនោះ ជាហេតុធ្វើខ្លួនឲ្យបានចំរើនលឿនទៅមុខជានិច្ច ។

៤ – ធ្វើកម្មដ៏លាមកក្នុងទីកំបាំងកុំបួលចិត្តថា មិនមានអ្នកណាឃើញមិនមានអ្នកណាដឹង ដូច្នេះមិនត្រូវទេ ព្រោះមនុស្សដទៃមិនឃើញ

មែន តែទេវតាគង់ឃើញ ឬជាគ្រឿងសៅហ្មងដល់ខ្លួនឯង ហេតុនេះ យើងមិនគួរធ្វើបាបទាំងក្នុងទីកំបាំង ទាំងក្នុងទីចំពោះមុខទេ ។

៥ – បើអ្នកណាមានសេចក្ដីស្ងប់កាយ-វាចា-ចិត្ត អ្នកនោះនឹងជាទីគាប់ចិត្តរបស់ទេវតានឹងមនុស្សទាំងឡាយ ។

៦ – បញ្ចក្ខន្ធតាំងនៅទីណា ទុក្ខក៏តាំងនៅទីនោះ, បញ្ចក្ខន្ធមានដរាបណា ទុក្ខក៏មានដរាបនោះ ព្រោះបញ្ចក្ខន្ធជាតួទុក្ខ មានទាំងសភាវទុក្ខ ទាំងបកិណ្ណកទុក្ខ គ្មានអ្នកណានឹងគេចវាងឲ្យផុតបានទេ ទាំងតាំងនៅយូរក៏មិនបាន នឹងត្រូវបែកធ្លាយទៅតាមសភាពរបស់សង្ខារ ។ បុគ្គលកាលបានដឹងដោយជាក់ច្បាស់ដូច្នេះហើយ មិនត្រូវប្រមាទក្នុងវ័យក្នុងជីវិតនឹងក្នុងសេចក្ដីមិនមានរោគ ត្រូវប្រញាប់ប្រញាល់ស្វែងរកសេចក្ដីល្អមកដាក់ខ្លួន ដើម្បីនឹងបានជាបច្ច័យទំនុកបំរុងខ្លួន ឲ្យនៅជាសុខក្នុងបច្ចុប្បន្ននឹងអនាគត រឿងនេះគួរមនសិការៈទុកក្នុងចិត្តឲ្យច្រើន ។

៧ – ផលដែលបុគ្គលប្រាថ្នា នឹងសម្រេចដោយអាការត្រឹមតែតាំងចិត្តប្រាថ្នាប៉ុណ្ណោះមិនបានទេ ដែលពិតត្រូវប្រកបព្រមដោយការធ្វើ កាលបើធ្វើហើយមិនទាន់គ្រប់គ្រាន់ គឺមានខ្វះខាតនៅឡើយ ត្រូវអាស្រ័យគ្រឿងឧបករណ៍ច្រើនយ៉ាងទៀត ដូចជាត្រូវធ្វើឲ្យជាអ្នកមានសតិ មានសេចក្ដីព្យាយាម នឹងមានសេចក្ដីអត់ធន់ជាដើម ទើបនឹងសម្រេចបានដូចចិត្តប្រាថ្នា ។

៨- មនុស្សគប្បីប្រញាប់ខ្វល់ខ្វាយធ្វើសេចក្ដីល្អ គប្បីហាមចិត្តចេញចាកសេចក្ដីអាក្រក់ ព្រោះថាកាលមនុស្សធ្វើសេចក្ដីល្អយឺតយូរពេក ចិត្តនឹងត្រេកអរទៅក្នុងសេចក្ដីអាក្រក់ ។

៩- សេចក្ដីសុខនៅត្រង់សេចក្ដីពេញចិត្ត សេចក្ដីទុក្ខនៅត្រង់សេចក្ដីមិនពេញចិត្ត ឬអាក់អន់ចិត្ត ។

១០. ជីវិតរបស់ខ្លួនជាទីស្រឡាញ់ដូចម្ដេច ជីវិតរបស់អ្នកដទៃក៏ជាទីស្រឡាញ់ដូច្នោះដែរ សប្បុរសយកខ្លួនទៅប្រៀបធៀបយ៉ាងនេះហើយ ទើបធ្វើសេចក្ដីមេត្តាករុណាចំពោះសត្វដែលមានជីវិតទូទៅ ។

១១- ទឹកដែលហូរចុះទៅកាន់ទីទាប មិនត្រឡប់ហូរច្រាសឡើងវិញដូចម្ដេច ថ្ងៃនិងយប់ដែលកន្លងទៅក៏នាំអាយុរបស់សត្វទៅរឿយៗ សព្វកាលដូច្នោះដែរ ។

១២- នឹងធ្វើនឹងនិយាយការអ្វីៗ ត្រូវពិចារណាឲ្យឃើញជាក់ច្បាស់ជាមុនសិន ទើបការធ្វើឬការនិយាយនោះនឹងបានកប់ប្រសប់ល្អ-ផលដ៏គាប់ចិត្ត ។

១៣- ក្លាហាន រឹងប៉ឹង អត់ធន់ គំនិតហ្មត់ចត់ ជាលក្ខណការរបស់មហាបុរស ។

១៤- អ្នកដែលកំណាញ់ណាស់នឹងលោភណាស់ ចាត់ជាមនុស្សពាលក្រណាស់. អ្នកដែលមានយុត្តិធម៌ណាស់ ចាត់ជាអ្នកមានព្រហ្មវិហារ ។

១៥ – កើតស្លាប់ជារបស់គូគ្នា អ្នកខ្លាចស្លាប់ចាត់ជាអ្នកខ្លាចកើត អ្នកមិនខ្លាចស្លាប់ ចាត់ជាអ្នកមិនខ្លាចកើត ៗ

១៦ – កាម ១ លោភ ១ ក្រោធ ១ ឫស្យា ១ មានះ ១ ស្រវឹង ១ កាលបើបុគ្គលលះបង់បានហើយ រមែងមានសេចក្ដីសុខ ៗ

១៧ – មនុស្សអាក្រក់ប្រៀបដូចភាជន៍ដី បែកធ្លាយងាយ ផ្សួសផ្សុលផ្សាបានដោយកម្រ តែមនុស្សល្អ ប្រៀបដូចភាជន៍មាស កម្រនឹងបែកធ្លាយ តែផ្សួសផ្សុលផ្សាបានដោយងាយ ៗ

១៨ – កាលបុរសសិក្សាគម្ពីរសាស្ត្រចប់ហើយ នៅតែជាមនុស្សវង្វេងងល់ក៏គង់មាន លុះកាលគេបានប្រតិបត្តិដោយប្រពៃហើយ ទើបរាប់ថាជាអ្នកចេះដឹង ប្រៀបដូចថ្នាំដែលពេទ្យគិតផ្សំយ៉ាងល្អ បើមានតែឈ្មោះប៉ុណ្ណោះ ក៏មិនអាចនឹងរក្សារោគរបស់មនុស្សឈឺឲ្យសះជាបាន ៗ

១៩ – សេចក្ដីព្រួយ ករែក ជាអន្តរាយចំពោះការងារទាំងអស់ គួរកែខៃដោយប្រការទាំងពួង ព្រោះដូច្នោះ កាលបើលះសេចក្ដីព្រួយហើយ គង់បានគប់ប្រសប់ផលដែលសម្រេចមកពីការងារ ៗ

២០ – អត្តគុណណា ដែលបុគ្គលបានកាន់ផ្លូវការចិញ្ចឹមជីវិត ទាំងមានសាធុជនសរសើរជាច្រើនក្នុងលោក អត្តគុណនោះគួរជម ទាំងគួរព្យាយាមប្រព្រឹត្តឲ្យជាភិយ្យោភាពឡើង ៗ

២១ – មនុស្សពាល ល្ងង់ខ្លៅ តែងគិតតែឧបក្រសោបសេចក្ដីវិនាសមកដាក់ខ្លួន មិនអាចស្គាល់ផ្លូវដែលនឹងឧបក្រសោបសេចក្ដីល្អមកដាក់ខ្លួនបានទេ, ក្នុងកាលមានអ្នកដទៃដាស់តឿនឲ្យធ្វើសេចក្ដីល្អ ជនពាលនោះច្រើនឃើញការដាស់តឿនរបស់អ្នកដទៃ ក្នុងផ្លូវដែលល្អ ថាជារបស់ខុសជានិច្ចទៅវិញ ។

២២ – អ្នកណាជាពាល ដឹងខ្លួនថាជាពាល អ្នកនោះនឹងត្រឡប់ជាបណ្ឌិតបានខ្លះ តែថាអ្នកណាជាពាល ត្រឡប់មានសេចក្ដីសំគាល់ថាខ្លួនជាបណ្ឌិតវិញ អ្នកនោះឯងលោកហៅថាជាមនុស្សពាលដោយពិត ។

២៣ – កាលលោកសន្និកស កំពុងឆេះរុងរឿងជានិច្ច លោកអ្នកទាំងឡាយ នឹងនាំគ្នារីករាយត្រេកត្រអាលដល់ណាទៀត លោកអ្នកទាំងឡាយ ដែលត្រូវងងឹតគឺអវិជ្ជាគ្របសង្កត់ហើយ ហេតុអ្វីមិនស្វែងរកប្រទីបគឺបញ្ញាទៀង ។